ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២៧៤ សជណ.ធឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពអាកាសធាតុ នៅព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុ រួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា ៖ ព្យុះទីហ្វុងឈ្មោះ **គោនី** ( GONI ) ដែលបានកើតឡើងនៅលើមហាសមុទ្រប៉ាស៊ីហ្វិក កាលពីថ្ងៃទី 17 ខែសីហា ឆ្នាំ 2015 នោះ បាន និងកំពុងបន្តដំណើរ ឆ្ពោះមកទិសខាងលិច ។ យោងតាមការព្យាករ ព្យុះនេះនឹងធ្វើដំណើរទៅដល់កោះតៃវ៉ាន់ នៅថ្ងៃទី 23 ខែសីហា ឆ្នាំ 2015 ។

ឥទ្ធិពលនៃកន្ទុយរបស់ព្យុះ **គោនី** រួមជាមួយខ្យល់មូសុងនិរតីខ្លាំង នឹងបង្កឱ្យ ៖

- មានភ្លៀងបន្តធ្លាក់រាយប៉ាយនៅព្រះរាជាណាចក្រកម្ពុជា ។
- នៅតំបន់មាត់សមុទ្រ រួមមានខេត្តកោះកុង ព្រះសីហនុ កែប និងខេត្តកំពត នឹងមានភ្លៀងធ្លាក់ច្រើន លាយឡំជាមួយខ្យល់កន្ត្រាក់ ។
- លើផ្ទៃសមុទ្រ មានខ្យល់បក់បោកខ្លាំង រលកសមុទ្រអាចមានកំពស់ពី 1,00 - 2,50 ម៉ែត្រ ។

ស្ថានភាពបែបនេះ នឹងកើតមានចាប់ពីថ្ងៃទី 22 ដល់ថ្ងៃទី 25 ខែសីហា ឆ្នាំ 2015 ។

យោងលើស្ថានភាពអាកាសធាតុ ដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ពិសេសចំពោះបងប្អូនប្រជានេសាទសមុទ្រ និងអ្នកធ្វើដំណើរតាមសមុទ្រ សូមបង្កើនការយកចិត្តទុកដាក់ខ្ពស់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៥

រដ្ឋមន្ត្រី

លឹម គានហោ